# ចំណាប់អារម្មណ៍របស់ខ្ញុំទៅលើកម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ខ្ញុំបាទឈ្មោះ ហ៊្សូរ ហាច ជានិស្សិតឆ្នាំទី១ នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាផ្នែកទំនាក់ទំនង។ ខ្ញុំបាទមានស្រុកកំណើតនៅ ភូមិបាតដីក្រោម ឃុំបឹងព្រួល ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។

បន្ទាប់ពីខ្ញុំបានតាមដានស្តាប់កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលកម្ពុជារួចមក ខ្ញុំពិតជាចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើកម្មវិធីវិទ្យុនេះ។ ការរៀបចំកម្មវិធីវិទ្យុនេះឡើង មិនត្រឹមតែផ្សព្វផ្សាយឱ្យអ្នកស្តាប់ដឹងកាន់តែច្បាស់អំពីសកម្មភាពឃោរឃៅ ដែលខ្មែរក្រហមបានធ្វើចំពោះប្រជាជនកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែ កម្មវិធីវិទ្យុនេះក៏បានលើកយកនូវសាច់រឿងដ៏កំសត់វេទនាផ្ទាល់ខ្លួនរបស់ជនរងគ្រោះដែលពាក់ពន្ធ័ទៅនឹងការអត់ឃ្លាន និងជាពិសេសទៅទៀតនោះ ជំរុញឱ្យមានការចូលរួមនៅក្នុងដំណើរការស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋដែលបានស្លាប់ និងរងគ្រោះក្នុងរបបដ៏យង់ឃ្នងនោះ។ ក្នុងនាមខ្ញុំជានិស្សិត ខ្ញុំបាទពិតជាមានសេចក្តីត្រេកអរយ៉ាងខ្លាំង ដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានខិតខំយកចិត្តទុកដាក់ក្នុងការផ្សព្វផ្សាយជូនដល់ប្រជាពលរដ្ឋគ្រប់រូបបានស្តាប់ និងជ្រាបកាន់តែច្បាស់បន្ថែមពីរបបដ៏សាហាវឃោរឃៅមួយនេះ។ ការសម្លាប់ប្រជាជនស្លូតត្រង់គ្មានត្រាប្រណីរបស់អង្គការបដិវត្តន៍ ការធ្វើទារុណកម្ម ការបង្ខិតបង្ខំឱ្យប្រជាជនធ្វើការហួសកំលាំង ការផ្តល់របបអាហារមិនគ្រប់គ្រាន់ គឺជាអ្វីដែលបានកើតឡើងនៅក្នុងរបបនោះប្រាដកមែន។ លើសពីនេះទៅទៀត ខ្ញុំក៏បានដឹងបន្ថែមដែរថា បទឧក្រិដ្ឋកម្មទាំងនោះក៏ធ្លាប់បានកើតឡើងនៅក្នុងប្រទេសមួយចំនួនរួចមកហើយ។ ក្រៅពីចំណេះដឹងទាក់ទងទៅនឹងប្រវត្តិនៃរបបខ្មែរក្រហម ខ្ញុំក៏បានដឹងបន្ថែមទាក់ទងទៅនឹងដំណើរការនៃតុលាការខ្មែរក្រហមផងដែរ។

ខ្ញុំបាទ ពិតជាមានការចាប់អារម្មណ៍ និងពេញចិត្តយ៉ាងខ្លាំងចំពោះកម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជានេះណាស់។ ការធ្វើការផ្សព្វផ្សាយនៃកម្មវិធីវិទ្យុនេះក៏បានគាស់រំលឹករឿងរ៉ាវដ៏ឈឺចាប់ទាំងឡាយរបស់ប្រជាជនកម្ពុជា ដែលបានឆ្លងកាត់ក្នុងសម័យនោះ ដើម្បីទុកជាបទ

ពិសោធន៍ប្រវត្តិសាស្ត្រ។ ប្រជាជនកម្ពុជាគួរតែស្តាប់ និងបន្តស្តាប់កម្មវិធីនេះ ព្រោះកម្មវិធីនេះនឹងធ្វើអោយយើងយល់ដឹងកាន់តែច្បាស់អំពីរបបនេះ។ ប្រជាជនកម្ពុជាទាំងអស់ក៏ជាសាក្សីដ៏សំខាន់ក្នុងការជំរុញឱ្យការកាត់ក្តីមេដឹកនាំខ្មែរក្រហម និងអ្នកដែលពាក់ពន្ធ័ ឱ្យកាន់តែរលូន និងឆាប់បញ្ចាប់ ដើម្បីស្វែងរកយុត្តធម៌ជូនជនរងគ្រោះស្លូតត្រង់។ ជាពិសេសទៅទៀតនោះ ប្រជាជនកម្ពុជាទាំងអស់ត្រូវចូលរួមទប់ស្កាត់ និងធ្វើយ៉ាងណាកុំអោយរបបនេះកើតឡើងក្នុងប្រទេសកម្ពុជាជាលើកទី២។

ក្នុងនាមខ្ញុំបាទជានិស្សិតម្នាក់ ខ្ញុំនឹងជួយធ្វើការផ្សព្វផ្សាយអំពីរបបនេះទៅកាន់ក្មេងជំនាន់ក្រោយដែលពុំទាន់ដឹងច្បាស់ពីរបបនេះ។ ខ្ញុំសូមសុំណូមពរឱ្យមានបន្ថែមថ្ងៃ និងម៉ោងចាក់ផ្សាយកម្មវិធីវិទ្យុនេះដើម្បីផ្តល់ឱកាសដល់ប្រជាពលរដ្ឋ ដែលពុំសូវមានពេលវេលាគ្រប់គ្រាន់ បានស្តាប់កម្មវិធីដ៏មានសារៈប្រយោជន៍នេះផង។

# My Personal Reflection on DC-Cam's Community Radio[1]

My name is Hour Hach. I am a freshman at Pannasastra University majoring in Media and Communications. I was born in Bartdey Krom village, Beung Pruol commune, Tbong Khmom district, Kampong Cham province. I am now living in Phnom Penh.

After listening to DC-Cam's community radio program "Voices of Genocide: Justice and Khmer Rouge Famine," I became very interested in the program. This program not only provide a platform of knowledge regarding to the harsh actions which the Khmer Rouge did toward Cambodians, but also shares victims' individual stories and famine issue in Cambodia and some other countries. Particularly, this program is a part of witnessing justice for innocent Cambodians who died and suffered from the harsh regime. I am glad that the Documentation Center of Cambodia (DC-Cam) is working energetically to educate people about the regime. Execution, torture, force labor, and famine are the cases in which really happened in the Cambodian society during the Khmer Rouge time. Moreover, throughout the program I understood also that such crimes have happened in some other countries. Besides, I can also gain more knowledge about the process of the Khmer Rouge Tribunal. This radio program recalls the painful individual stories of Cambodians as historical experiences. I think it is good for Cambodians to listen to the program since it would help you learn more about the regime.  Cambodian people are important witnesses for the process of the Khmer Rouge Tribunal in the meaning of witnessing justice. Cambodian people should find ways to prevent genocide from happening again.

As a university student, I want to share my knowledge regarding the Khmer Rouge history to younger generations who has less knowledge and understanding about the regime. And I would also like to ask DC-Cam to add more days into broadcast program so that the audiences who are very busy with work would have more chances on listening to this beneficial program.

[1] Edited by Sreyneath Poole